pennsylvania
DEPARTMENT OF COMMUNITY
& ECONOMIC DEVELOPMENT

**សម្រាប់ការចេញផ្សាយភ្លាម**
**ថ្ងៃទី 20 ខែមីនា ឆ្នាំ 2020**

**ការពន្យារពេលការលើកលែង រយៈពេលអនុវត្តដែលបានកែប្រែ៖ ថ្ងៃច័ន្ទ ទី 23 ខែមីនាវេលា ម៉ោង 8:00 ព្រឹក**
ការណែនាំអាជីវកម្មដែលបានធ្វើបច្ចុប្បន្នភាព
ពាក្យសុំសិទ្ធិលើកលែងរបស់អាជីវកម្ម
សំណួរសួរញឹកញាប់អំពីការណែនាំសម្រាប់អាជីវកម្ម

**Harrisburg, PA** – ដោយសារការស្នើសុំការលើកលែងមានចំនួនច្រើន រដ្ឋបាលរបស់ Wolf កំពុងពន្យារពេលការអនុវត្តបទបញ្ជារបស់អភិបាល Tom Wolf និង បទបញ្ជារបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាលដែលចែងថា រាល់អាជីវកម្មប្រភេទមិនទ្រទ្រង់ជីវិតនៅក្នុងរដ្ឋ Pennsylvania ត្រូវតែបិទទីតាំងជាក់ស្តែងរបស់ពួកគេ ដើម្បីបន្ថយការរីករាលដាលនៃវីរុសកូវីដ 19។

តាមបទបញ្ជារបស់អភិបាល Wolf និងវេជ្ជបណ្ឌិត Levine អាជីវកម្មប្រភេទមិនទ្រទ្រង់ជីវិតត្រូវបានបញ្ជាឱ្យបិទទីតាំងជាក់ស្តែងរបស់ពួកគេនៅថ្ងៃទី 19 ខែមីនា វេលាម៉ោង 8:00 យប់។ បទបញ្ជានេះមានសុពលភាព ហើយមានតែពេលវេលានៃការអនុវត្តប៉ុណ្ណោះនឹងផ្លាស់ប្តូរ និងចាប់មានប្រសិទ្ធភាពនៅថ្ងៃច័ន្ទទី 23 ខែមីនាវេលាម៉ោង 8:00 ព្រឹក។

អាជីវកម្មទាំងឡាយដែលស្នើសុំការបញ្ជាក់អំពីថាតើអាជីវកម្មនោះត្រូវបានកំណត់ជាអាជីវកម្មប្រភេទទ្រទ្រង់ជីវិតឬអត់ គួរតែពិនិត្យមើលបញ្ជីនេះ និងផ្ញើ អ៊ីមែលទៅគណនីផនផានសេវាកម្មបម្រើអតិថិជនរបស់ផ្នែកអភិវឌ្ឍសហគមន៍ និងសេដ្ឋកិច្ច (DCED) តាមអាសយដ្ឋាន ra-dcedcs@pa.gov ឬទូរស័ព្ទទៅលេខ 1-877-PA-HEALTH ហើយជ្រើសរើសជម្រើសទី 1 ដើម្បីទាក់ទងបុគ្គលិក DCED ។ ចំពោះអាជីវកម្មដែលកំណត់ពីបញ្ជីនេះដែលបញ្ជាក់ថាអាជីវកម្មមិនមែនជាអាជីវកម្មប្រភទទ្រង់ទ្រង់ជីវិត ប៉ុន្តែចង់ស្វែងរកការលើកលែង មានពាក្យសុំសិទ្ធិលើកលែងតាមអនឡាញ។

នៅពេលអាជីវកម្មបានបំពេញពាក្យសុំសិទ្ធិលើកលែង ក្រុមអ្នកជំនាញនៅ DCED នឹងពិនិត្យសំណើនីមួយៗ និងឆ្លើយតបដោយផ្អែកលើគោលការណ៍ណែនាំអំពីការរក្សាតុល្យភាពនៃសុវត្ថិភាពសាធារណៈដោយធានាការបន្តផ្តល់សេវា និងមុខងារហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ។ អ្នកដែលស្នើសុំការលើកលែងនឹងត្រូវបានជូនដំណឹងតាមរយៈអ៊ីមែលប្រសិនបើប្រតិបត្តិការរបស់ពួកគេអាចបើកម្តងទៀត។ អាជីវកម្មដែលស្នើសុំសិទ្ធិលើកលែងត្រូវតែនៅបិទរហូតដល់មានការសម្រេចចិត្តអំពីពាក្យសុំរបស់ពួកគេ។

DCED ផ្តល់ជូននូវប្រាក់កម្ចីដើមទុនបង្វិលដែលអាចជាជំនួយដល់អាជីវកម្មដែលរងផលប៉ះពាល់ដោយវីរុសកូវីដ 19 ។ ធនធាន និងព័ត៌មាននឹងត្រូវបានបង្ហោះទៅគេហទំព័រ http://dced.pa.gov/resources នៅពេលដែលមាន។ កាលពីម្សិលមិញ លោកអភិបាល Wolf បានប្រកាសថា មានប្រាក់កម្ចីការប្រាក់ទាបសម្រាប់អាជីវកម្មខ្នាតតូច និងអង្គការមិនរកប្រាក់ចំណេញស្របច្បាប់នៅគ្រប់ 67 ខោនធីក្នុងរដ្ឋ Pennsylvania តាមរយៈរដ្ឋបាលអាជីវកម្មខ្នាតតូចសហរដ្ឋអាមេរិក (SBA)។

ដើម្បីទទួលបានព័ត៌មានថ្មីៗបំផុតអំពីវីរុសកូវីដ19 ប្រជាពលរដ្ឋ Pennsylvania គួរតែតាមដាននៅលើ www.governor.pa.gov និង www.doh.pa.gov។

**ទំនាក់ទំនងប្រព័ន្ធផ្សព្វផ្សាយ៖** Casey Smith, casesmith@pa.gov

###